អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទស្សនៈអ្នកពុទ្ធសាសនាចំពោះ
## ការកាត់ទោសខ្មែរក្រហម ។

www.hoksavann.org

ថ្ងៃទី២ ធ្នូ ២០១១



ប្រជាពលរដ្ឋខ្មែរត្រូវពួកឃាតករខ្មែរក្រហមសម្លាប់ នៅពេលដែលប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមនៅថ្ងៃ១៧ មេសា ១៩៧៥ ។ ពលរដ្ឋខ្មែរមានការធុញទ្រាន់នឹងសង្គ្រាម៥ឆ្នាំ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ ប៉ុន្តែគួរឲ្យរន្ធត់ នៅពេលចប់សង្គ្រាម បែរជាទទួលរងទុក្ខវេទនាខ្លាំងជាងសង្គ្រាមរាប់រយពាន់ដងទៅទៀត ។ អ្នកដែលបានផុតពីស្លាប់បាននិយាយថា ៖ ទុក្ខវេទនាដែលខ្មែរក្រហមធ្វើបាប ភាសាមនុស្សពុំអាចនិយាយឲ្យអស់បានឡើយ ។ ពួកវាបានដេញប្រជាពលរដ្ឋពីទីក្រុងនានា ជាពិសេសពីទីក្រុងភ្នំពេញ ដូចដេញហ្វូងគោហ្វូងក្របី អត់បាយអត់ទឹក គ្មានទីជម្រក ខ្លះដួលដេកស្លាប់កណ្តាលផ្លូវ ។ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនាក៏ត្រូវចាកចេញពីវត្តដូចពលរដ្ឋនានាដែរ ។ ព្រះអង្គខ្លះត្រូវសឹកតាមផ្លូវ អង្គខ្លះដែលមានឋានៈត្រូវពួកវាចាប់យកទៅបាត់ ។ គ្រាន់តែផ្តើមឧក្រិដ្ឋកម្មដំបូង ដោយការដេញប្រជាជនចេញពីលំនៅរបស់ខ្លួន ចាត់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ខុសច្បាប់អន្តរជាតិទៅហើយ ។ នួន-ជា មេទ្រឹស្តីកុម្មុយនិស្តបាននៅក្នុងរង្វង់ក្រចកសេះ ដែលត្រូវតុលាការខ្មែរនិងអង្គការសហប្រជាជាតិ យកមកកាត់ទោសជាមួយនឹងមេខ្មែរក្រហមពីរនាក់ទៀត គឺខៀវ-សំផន និងអៀង-សារី នៅថ្ងៃ២៣ វិច្ឆិកា ២០១១ បាននិយាយថា សហព្រះរាជអាជ្ញាខ្មែរនិងបរទេសចោទគាត់គ្មានការពិតទេ គ្មានសាក្សីអ្វីទេ ចេះតែថាតាមតែពួកកាសែត ។ យើងសូមឆ្លើយទៅមេឃាតករនួន-ជាថា ប្រជាពលរដ្ឋខ្មែរទាំងមូលជាសាក្សី ព្រោះប្រជាពលរដ្ឋខ្មែរទាំងអស់ គ្រប់ក្រុមគ្រួសារ ត្រូវទទួលរងទុក្ខវេទនា ដោយសារពួកមិច្ឆាទិដ្ឋិអមនុស្សធម៌របស់ខ្មែរក្រហម ។

បន្ទាប់ពីទុក្ខវេទនាដោយការដេញចេញពីផ្ទះ ពួកខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ទាហានសាធារណរដ្ឋខ្មែរ ដោយបញ្ឆោតថា យកទៅទទួលសម្តេចសីហនុពីស័ក្តិមួយឡើងទៅ ក្រោយមកសម្លាប់ទាំងអស់ឲ្យតែធ្វើទាហាន សូម្បីធ្វើមួយថ្ងៃក៏ដោយ ។ ចំពោះប្រជាជនទូទៅ បានត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ និងបង្អត់អាហារ ។ ប្រជាជនខ្លះបានត្រូវសម្លាប់ដោយចោទថាខ្មាំង ខ្លះស្លាប់ដោយអត់អាហារ ខ្លះស្លាប់ដោយជម្ងឺគ្មានថ្នាំព្យាបាល ។ ប្រជាជនទាំងអស់ជាទាសករ គ្មានសិទ្ធិអ្វីឡើយ ។ ចំពោះព្រះពុទ្ធសាសនា ពួកខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃសឹកទាំងអស់ បើអង្គណានៅរួញរាមិនព្រមសឹក ខ្មែរក្រហមបានធ្វើគត់ ។ នៅចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦ ព្រះសង្ឃក្នុងកម្ពុជាទាំងមូលត្រូវសឹកទាំងអស់ ។ វត្តអារាម ព្រះពុទ្ធរូប គម្ពីរព្រះពុទ្ធសាសនា បានត្រូវពួកខ្មែរក្រហមបំផ្លាញចោលស្ទើរគ្មានសល់ ។ ពត៌មានដោយសង្ខេបនេះ បានមកពីពុទ្ធសាសនិកជនខ្មែរបានដំណាលប្រាប់ប្រហាក់ប្រហែលគ្នា ។

នួន-ជាបានបដិសេធនូវអំពើឧក្រិដ្ឋរបស់ខ្លួន ប៉ុន្តែពាក្យនិយាយហាក់ដូចទទួលសារភាព ដូចអំពើដេញប្រជាជន និងការកំទេចខ្មាំង ។ អៀង-សារីធ្វើមិនដឹង មិនចង់និយាយ ។ ចំណែកខៀវ-សំផននិយាយបង្វែងដានថា ខ្លួនគ្មានអំណាចអ្វីទេពេលនោះ ។ ការពិតឯកសារចំនួន៥សែនទំព័រ រូបភាពជារូបថត រណ្តៅកប់ខ្មោចជាច្រើនរណ្តៅ និងឯកសារទំនាក់ទំនងរវាងថ្នាក់ដឹកនាំមជ្ឈិមបក្ស ដែលលោកឆាំង-យុ ប្រធានគណៈកម្មាធិការស្រាវជ្រាវឧក្រិដ្ឋកម្មខ្មែរក្រហមបានរកឃើញ អាចដាក់បន្ទុកបានពេញបរិបូណ៌ ។ ពួកទាហានបានដាក់អាវុធ សុខចិត្តចុះចាញ់ ត្រូវពួកខ្មែរក្រហមយកទៅបាញ់ចោល នេះឧក្រិដ្ឋកម្មក្នុងសង្គ្រាម ។ ចំណែកប្រជាជនស្លូតត្រង់គ្មានអាវុធក្នុងដៃសុខចិត្តធ្វើតាមរបបថ្មី ត្រូវខ្មែរក្រហមសម្លាប់យ៉ាងសាហាវ នេះជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិខុសច្បាប់អន្តរជាតិ ។

នួន-ជាបាននិយាយចោទវៀតណាមនិងមហាអំណាចដទៃទៀតថា បានធ្វើឲ្យខ្មែរមានសោកនាដកម្មនេះ ។ បើដូច្នេះមែន ហេតុអ្វីបានជាខ្មែរក្រហមមិនប្រកាសប្រាប់ពិភពលោកថា វៀតណាមបានសម្លាប់ប្រជាជនខ្មែរ នៅខេត្តនេះអស់ប៉ុណ្ណោះនៅខេត្តនោះអស់ប៉ុណ្ណោះជាដើម នៅពេលដែលខ្លួនកាន់អំណាច ដើម្បីឲ្យពិភពលោកជួយធ្វើអន្តរាគមន៍ ។ នួន-ជាថា អំពើដែលខ្លួនធ្វើទាំងប៉ុន្មាននៅពេលកាន់អំណាច គឺដើម្បីការពារប្រទេសកម្ពុជាពីការឈ្លានពានរបស់បរទេស ។ ពាក្យស្នេហាជាតិស្រឡាញ់ជាតិ ស្រួលថាណាស់ ប៉ុន្តែលទ្ធផលនៃការស្នេហាជាតិរបស់ខ្មែរក្រហម ខ្មែរបានស្លាប់រាប់លាននាក់ ហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិ រួមទាំងវប្បធម៌ សាសនា ត្រូវខ្មែរក្រហមបំផ្លាញស្ទើរគ្មានសល់ ។ តាមពិតខ្មែរក្រហមជាជនមិច្ឆាទិដ្ឋិ ជាជនអវិជ្ជា គ្មានសីលធម៌ បំរើមនោគមវិជ្ជាកុម្មុយនិស្ត ព្រៃផ្សៃគ្មានសីលធម៌ ដើរបញ្ច្រាសការជឿនលឿនរបស់ពិភពលោក ។ ខ្លួនមានជ័យជំនះដោយសារតែយកព្រះនាមសម្តេចសីហនុជាមធ្យោបាយ ដោយការភ័ន្តច្រឡំរបស់ប្រជារាស្ត្រខ្មែរ និងដោយការប្រែប្រួលនៃពិភពលោក ជាពិសេសគំនិតដូរផ្លាស់នៃមហាអំណាច ។ សង្គ្រាម៥ឆ្នាំរបស់កម្ពុជាពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ជាសង្គ្រាមគំនុំសងសឹករបស់ខ្មែរក្រហមមកលើពលរដ្ឋខ្មែរ ។ ដូច្នេះហើយបានជាពេលមានជ័យជំនះភ្លាម ខ្មែរក្រហមចាប់អនុវត្តផែនការកំទេចខ្មាំងសត្រូវវណ្ណៈ គឺចក្រពត្តិមូលធនសក្តិភូមិ ។ សក្តិភូមិគឺអ្នកចេះដឹង រួមទាំងសាសនាផង ។ ចំពោះមុខតុលាការចំរុះ ទោះបីខ្មែរក្រហមដោះសារយ៉ាងណាក៏ដោយ មានឯកសារនិងភស្តុតាងជាសក្ខីកម្មជាច្រើនសំរាប់កាត់ទោសដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះខ្មែរមួយនគរកម្ពុជា ។

ចំពោះតុលាការចំរុះរវាងខ្មែរនិងអង្គការសហប្រជាជាតិបាននិយាយគ្នាហើយថា កាត់ទោសតែខ្មែរក្រហមជាកម្មាភិបាលជាន់ខ្ពស់ ដូចជាសមាជិកមជ្ឈិមបក្ស និងអ្នកដៃដល់សម្លាប់ខ្មែរមានចំនួនច្រើន លើកលែងមិនកាត់ទោសបរទេសនៅពីក្រោយឡើយ ។ ការកាត់ទោសមានកំណត់ព្រំដែនដូច្នេះ គេហៅថាកាត់ទោសតាមផ្លូវនយោបាយ ។ បើកាត់ទោសតាមផ្លូវយុត្តិធម៌វិញ គឺគេកាត់ទោសតាមតែឯកសារជាភស្តុតាងបានចង្អុលប្រាប់ ចំពោះជនណាក៏ដោយឲ្យតែមានកំហុសត្រូវតែកាត់ទោស ។

ចំពោះយើងជាអ្នកកាន់ព្រះពុទ្ធសាសនា សូមគាំទ្រតុលាការនេះ ទោះបីយើងសង្កេតឃើញថា តុលាការនេះពុំអាចរកយុត្តិធម៌ជូនអ្នករងគ្រោះឲ្យពេញបរិបូណ៌ក៏ដោយ ។ ការរកយុត្តិធម៌នេះ ជាកាតព្វកិច្ចរបស់ប្រទេសប្រជាធិបតេយ្យនិងប្រទេសមាននីតិរដ្ឋ ។ បានសេចក្តីថា អ្នកមានកំហុសត្រូវតែផ្តន្ទាទោស អ្នករងគ្រោះត្រូវតែលើកតម្កើង បង្កើតការអាណិតអាសូរ និងជួយឧបត្ថម្ភ ។ បើមិនរកយុត្តិធម៌ទេ អ្នកដែលធ្វើបាបគេត្រូវរួចខ្លួន ឯអ្នករងគ្រោះនៅតែរងគ្រោះគ្មានច្បាប់ជួយការពារឡើយ ។ ការគាំទ្រតុលាការរបស់អ្នកកាន់ព្រះពុទ្ធសាសនានេះ មិនឈ្មោះថាចងពៀរនឹងខ្មែរក្រហមឡើយ ព្រោះតុលាការទេដែលរកយុត្តិធម៌ រកខុសរកត្រូវ និងធ្វើទោសតាមកំហុស ពុំមែនអ្នកកាន់ពុទ្ធសាសនាឡើយ គឺច្បាប់របស់ប្រទេស និងច្បាប់អង្គការសហប្រជាជាតិទេ ដែលសំរេចសេចក្តីទៅជាយ៉ាងណា ។ មិនថាតែផ្លូវអាណាចក្រទេ ដែលតុលាការបំពេញកិច្ចនេះ ផ្លូវពុទ្ធចក្រ ពេលព្រះសង្ឃប្រព្រឹត្តខុសវិន័យ ថេរសភាសង្ឃ ឬវិន័យធរ បានសំរេចកាត់សេចក្តីព្រះសង្ឃណាដែលប្រព្រឹត្តខុសវិន័យ ។ ដូច្នេះ ថេរសភាសង្ឃដែលទុកជាតុលាការកាត់សេចក្តីព្រះសង្ឃមានកំហុស ពុំបានន័យថា ថេរសភាសង្ឃចងពៀរនឹងព្រះសង្ឃមានកំហុសនោះឡើយ តែបានសេចក្តីថា ដាក់កំហុសព្រះសង្ឃដែលធ្វើខុស លើកតម្កើងព្រះសង្ឃដែលប្រព្រឹត្តត្រឹមត្រូវតាមវិន័យ ដើម្បីឲ្យព្រះសង្ឃគ្រប់រូបបរិសុទ្ធ ។

អំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ទោះបីតុលាការបច្ចុប្បន្នមិនបានកាត់ទោស ក៏ពួកឧក្រិដ្ឋនេះនឹងត្រូវទទួលទោសក្នុងពេលខាងមុខតាមច្បាប់កម្មផលដែលជាច្បាប់ធម្មជាតិមានយុត្តិធម៌បំផុតពុំខានឡើយ។របបខ្មែរក្រហមឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩បានរលត់ហើយ ប៉ុន្តែយើងនៅព្រួយបារម្ភចំពោះខ្មែរក្រហមទំនើបថ្មី ដែលពាក់អាវប្រជាធិបតេយ្យ តែរំលោភសិទ្ធិមនុស្សធ្វើបាបពលរដ្ឋរបស់ខ្លួន រំលោភយកដីធ្លីប្រជាពលរដ្ឋ ថែមទាំងប្តឹងដាក់គុកថែមទៀត ។ ពីមុនមានអ្នកលួចបាញ់អ្នកសារពត៌មាននិងអ្នកប្រឆាំងអាជ្ញាធរបិទមិនរកមុខ ឥឡូវនេះឃើញមធ្យោបាយថ្មី គឺតុលាការកាត់សេចក្តីឲ្យអ្នកធំអ្នកមានអំណាចអ្នកមានដុល្លារឈ្នះជានិច្ច បើមានរឿងរ៉ាវជាមួយប្រជាជនធម្មតា ឬពីអ្នកប្រឆាំង ។ យើងសូមបួងសួង សូមខ្មែរគ្រប់រូបទុកប្រយោជន៍ជាតិជាធំ ឈប់កំចាត់គ្នា នៅចំពោះមុខចោរឈ្លានពានទឹកដី ។៚

* *

*